# ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
លេខ : ០៤៥៧/២០ ក.ប/ស.ណ.ន.ខ.ល

## សេចក្តីណែនាំ
## ស្តីពី
## ការការពារសុខភាព និងជីវភាពរបស់បងប្អូនពលករ ដែលកំពុងស្នាក់នៅ និងធ្វើការនៅបរទេស ឬបានវិលត្រឡប់មកភូមិកំណើតវិញ ក្នុងអំឡុងពេលការទប់ស្កាត់ការរាតត្បាតជំងឺកូវីដ-១៩

ក្នុងគោលបំណងការពារសុខភាព សុវត្ថិភាព និងជីវភាពរបស់បងប្អូនពលករខ្មែរ ដែលកំពុងធ្វើការនៅបរទេសក្នុងអំឡុងពេលរាតត្បាតជំងឺកូវីដ-១៩ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមណែនាំដល់បងប្អូនពលករខ្មែរ ដែលកំពុងស្នាក់នៅ និងធ្វើការនៅបរទេស ឬបានវិលត្រឡប់មកភូមិកំណើតវិញដូចខាងក្រោម៖

**ក. ពលករខ្មែរ ដែលកំពុងស្នាក់នៅ និងធ្វើការនៅបរទេស**

១. ត្រូវអនុវត្តតាមច្បាប់ បទបញ្ជា និងវិធានការសុខភាពនានាដែលបានដាក់ចេញដោយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសដែលបងប្អូនកំពុងធ្វើការ។

២. ត្រូវអនុវត្តតាមការណែនាំ ឬសេចក្តីជូនដំណឹងរបស់ស្ថានឯកអគ្គរាជទូត ឬអគ្គកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសដែលបងប្អូនកំពុងធ្វើការ។

៣. ត្រូវខិតខំបំពេញការងាររបស់ខ្លួនតាមការណែនាំរបស់អាជ្ញាធរមានសមត្ថកិច្ច និងនិយោជករបស់ខ្លួន។

៤. ត្រូវទាក់ទងទៅស្ថានឯកអគ្គរាជទូត ឬអគ្គកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជាជាបន្ទាន់ក្នុងករណីមានបញ្ហា។

**ខ. ពលករខ្មែរ ដែលបានវិលត្រឡប់មកព្រះរាជាណាចក្រកម្ពុជាវិញ**

១. ត្រូវអនុវត្តតាមការណែនាំរបស់អាជ្ញាធរមានសមត្ថកិច្ចនៅតាមច្រកទ្វារព្រំដែនគោក និងអាកាស ដើម្បីអនុវត្តវិធានការត្រួតពិនិត្យសុខភាព និងចត្តាឡីស័កចំនួន ១៤ថ្ងៃ នៅពេលទៅដល់ស្រុកកំណើតវិញ ស្របតាមនីតិវិធីដែលកំណត់ដោយក្រសួងសុខាភិបាល និងក្រុមការងាររាជធានី-ខេត្តនៃក្រសួងមហាផ្ទៃ។

២. ករណីបងប្អូនពលករ មានបញ្ហាជីវភាពរស់នៅប្រចាំថ្ងៃក្នុងអំឡុងពេលការរាតត្បាតជំងឺកូវីដ-១៩ ត្រូវទំនាក់ទំនងជាមួយអាជ្ញាធរមូលដ្ឋានរបស់ខ្លួន ដើម្បីទទួលបានសេវាអន្តរាគមន៍។ ករណីមានបំណងស្វែងរកការងារថ្មីធ្វើ ត្រូវទាក់ទងទៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងមជ្ឈមណ្ឌលការងារ រាជធានី-ខេត្ត ដើម្បីទទួលបានព័ត៌មានការងារ។

៣. សូមចូលរួមជួយក្រុមគ្រួសារដើម្បីធ្វើស្រែចំការ ដាំដុះ និងរបរកសិកម្មផ្សេងទៀត ក្នុងអំឡុងពេលរងចាំស្វែងរកការងារថ្មីធ្វើនៅក្នុងស្រុក ឬចង់វិលត្រឡប់ទៅក្រៅប្រទេសវិញ។

សូមបងប្អូនពលករខ្មែរទាំងអស់ ដែលកំពុងស្នាក់នៅ និងធ្វើការនៅបរទេស ឬបានវិលត្រឡប់មកភូមិកំណើតវិញចូលរួមអនុវត្តតាមសេចក្តីណែនាំនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ អង្គារ ៧ កើត ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែមេសា ឆ្នាំ ២០២០
**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**